ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

********

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រ.ក/លេខ ០៩.១០៦/១៣ គ.ជ.ប.អគ្គ.ពស

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣

## លទ្ធផលផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព “ក” មួយចំនួននៅមណ្ឌលខេត្តកណ្ដាលមិនមានអ្វីប្រែប្រួលឡើយ

តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ៣១/២០១៣ កបធ.សសរ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ នៅវេលាម៉ោង ៨:០០នាទី ព្រឹកថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ០៨ការិយាល័យនៅមណ្ឌលខេត្តកណ្ដាល ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងទម្រង់បែបបទលេខ ១១០២ ១១០៨ និងក្រដាសកត់ត្រាសំឡេងឆ្នោត ។

លោក ហ៊ឹ រ៉ុង ប្រធាននាយកដ្ឋានប្រតិបត្តិការបានប្រាប់អ្នកសារព័ត៌មានថា នៅពេលបើកកញ្ចប់សុវត្ថិភាព "ក" ទាំង ០៨ការិយាល័យនៅក្នុងមណ្ឌលខេត្តកណ្ដាល គឺឃើញថាមានការវេចខ្ចប់ត្រឹមត្រូវតាមនីតិវិធី ហើយលទ្ធផលនៃការផ្ទៀងផ្ទាត់ទម្រង់លេខ ១១០២ ១១០៨ និងក្រដាសកត់ត្រាសំឡេងឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ដូចគ្នាទៅនឹងលទ្ធផលបណ្ដោះអាសន្នដែល គ.ជ.ប បានផ្សាយកន្លងមក ប៉ុន្តែការសម្រេចយ៉ាងណានោះ ស្ថិតលើសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកសម្រេច ។

លោកបានបញ្ជាក់បន្ថែមទៀតថា ចំពោះការិយាល័យមួយក្នុងចំណោមការិយាល័យទាំង០៨ បានដាក់ទម្រង់លេខ ១១០១ ដល់ទៅពីរច្បាប់នៅក្នុងស្រោមសំបុត្រនោះ មិនមែនជាកំហុសអ្វីធ្ងន់ធ្ងរទេ គឺជាការឆេកល្វែងរបស់មន្ត្រីការិយាល័យបោះឆ្នោតក្នុងការច្រកស្រោមសំបុត្រតែប៉ុណ្ណោះ ។

ការិយាល័យដែលបើកកញ្ចប់សុវត្ថិភាព "ក" នៅសង្កាត់តាខ្មៅនៃមណ្ឌលខេត្តកណ្ដាល រួមមាន ៖

- ការិយាល័យលេខ ១០៦៨ ការិយាល័យលេខ ១០៧១
- ការិយាល័យលេខ ០៨៣៣ ការិយាល័យលេខ ១១៨១
- ការិយាល័យលេខ ១១៥៦ ការិយាល័យលេខ ១២៣៨
- ការិយាល័យលេខ ១២៩១ ការិយាល័យលេខ ១២៩២

សូមបញ្ជាក់ថា ការផ្ទៀងផ្ទាត់នេះ បានប្រព្រឹត្តទៅនៅទីស្តីការ គ.ជ.ប ហើយក៏មានការចូលរួមពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងគណបក្សនយោបាយ អង្គការសង្កេតការណ៍ជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិផងដែរ ៕

ទំនាក់ទំនងព័ត៌មាន ៖ ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ ; E-mail: necinfo@forum.org.kh ; www.necelect.org.kh